ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ........................................................

# សុន្ទរកថា

## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០០៩ របស់ធនាគារជាតិនៃកម្ពុជា

នៅធនាគារជាតិនៃកម្ពុជា នាថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩

សូមគោរព :

- គណៈអធិបតី
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីស្នេហា

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអតិបរមា ដោយបានមកជួបជាមួយ លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាមន្ត្រីបុគ្គលិករបស់ធនាគារជាតិនៃកម្ពុជា ដែលបានចូលរួមក្នុងសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០០៩ របស់ធនាគារជាតិនៃកម្ពុជា ។ នេះ គឺជាពិធីជាប្រពៃណីដែលយើងតែងតែប្រារព្ធធ្វើជារៀងរាល់ឆ្នាំ ដើម្បីបូកសរុបលទ្ធផលការងារ និងលើកទិសដៅសម្រាប់អនុវត្ត ។ ខ្ញុំសូមស្វាគមន៍ យ៉ាងកក់ក្តៅចំពោះវត្តមានរបស់លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាតំណាងនាយកដ្ឋាននានា នៅទីស្នាក់ការកណ្តាល និងសាខាធនាគារជាតិនៃកម្ពុជាខេត្ត-រាជធានី ដែលបានអញ្ជើញចូលរួមក្នុងអង្គសន្និបាតរបស់យើង នាពេលនេះ ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរយ៉ាងខ្លាំង ចំពោះកិច្ចខិតខំប្រឹងប្រែងប្រកបដោយស្មារតីទទួលខុសត្រូវរបស់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាយើងទាំងអស់គ្នា ក្នុងពេលបំពេញការងារ ដើម្បីរួមចំណែកកសាងសមិទ្ធផល ជូនធនាគារជាតិនៃកម្ពុជា កន្លងមក *ពោលគឺ* បានកសាងប្រព័ន្ធធនាគារយើងឱ្យមានការរីកចម្រើន មានសុខភាពល្អ មានសុវត្ថិភាព និងបានទទួលការជឿទុកចិត្តបន្ថែមទៀត ពីសាធារណជនទូទៅ ពីរាជរដ្ឋាភិបាល និងពីសហគមន៍អន្តរជាតិ ។

លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

គោលបំណងសំខាន់នៃការរៀបចំសន្និបាតរបស់យើងថ្ងៃនេះ គឺដើម្បីផ្សព្វផ្សាយពី :

១- សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជានៅឆមាសទី១ ឆ្នាំ២០០៩

២- លទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាអនុវត្តបានក្នុងឆមាសទី១ និងទិសដៅដែលយើងត្រូវបន្តអនុវត្ត នៅក្នុងឆមាសទី២ ឆ្នាំ២០០៩ ។

## I- សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជាក្នុងឆមាសទី១

ខ្ញុំសូមឆ្លៀតយកឱកាសនេះជម្រាបថា នៅឆ្នាំនេះ ពិភពលោកយើងប្រឈមមុខនឹងបញ្ហាធំៗមួយចំនួន ដូចជា *១)*-ឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចជុំទី២ដែលបណ្តាលមកពីវិបត្តិហិរញ្ញវត្ថុសកលលោក *២)*-និន្នាការឈានទៅរកការប្រែប្រួលការប្រើដុល្លារអាមេរិក ធ្វើជាទុនបម្រុងអន្តរជាតិចំបង *៣)*-ការបន្ថែមកញ្ចប់ថវិការដ្ឋដើម្បីជម្រុញកំណើនសេដ្ឋកិច្ច *៤)*-ការប្រែប្រួលតួនាទីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) *៥)*-ការប្រយុទ្ធនឹងការប្រែប្រួលអាកាសធាតុនិងយុទ្ធសាស្ត្រធ្វើអាជីវកម្មដោយមានកិច្ចការពារបរិដ្ឋាន *៦)*-បាតុភូតជំងឺគ្រុណផ្តាសាយជ្រូក (Swine Flu H1N1) និង*៧)*-ការរើបឡើងវិញនៃថ្លៃប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ ។ កត្តាទាំងនេះហើយដែលប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចពិភពលោក ។

នៅឆមាសទី១ ឆ្នាំ២០០៩ នេះ យោងតាមរបាយការណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានបង្ហាញថា សេដ្ឋកិច្ចពិភពលោកនឹងធ្លាក់ចុះដល់ -១.៣% ធៀបនឹងអត្រា ៤.១% នៅឆមាសទី១ ឆ្នាំ២០០៨ ដោយអត្រាកំណើនសេដ្ឋកិច្ចអាមេរិកនឹងធ្លាក់ត្រឹមកម្រិត -២.៨% សហគមន៍អឺរ៉ុប -៤.២% ប្រទេសជប៉ុន -៦.២% ប្រទេសចិន ៦.៥% និងប្រទេសឥណ្ឌា ៤.៥% ។ ចំណែកកំណើនសេដ្ឋកិច្ចនៃក្រុមប្រទេសអាស៊ាន នឹងកើនក្នុងកម្រិត ០.៦% ធៀបអត្រានឹង ៥.១% នៅឆមាសទី១ ឆ្នាំ២០០៨ ។

ចំពោះសេដ្ឋកិច្ចកម្ពុជាវិញ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានប្រសាសន៍ថា យើងត្រូវខិតខំសម្រេចឱ្យបានអត្រាកំណើនសេដ្ឋកិច្ច ៦% នៅឆ្នាំ២០០៩ នេះ ខណៈស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចត្រូវបានទ្រទ្រង់ដោយការថយចុះសម្ពាធអតិផរណា និងស្ថិរភាពអត្រាប្តូរប្រាក់ជាបន្តបន្ទាប់ ។ វិបត្តិសេដ្ឋកិច្ចបានជះឥទ្ធិពលដោយប្រយោលទៅលើវិស័យពិតនៃសេដ្ឋកិច្ច ដូចជា វិស័យកាត់ដេរ ទេសចរណ៍ សំណង់ និងវិនិយោគផ្ទាល់បរទេស ដែលធ្វើឱ្យផលិតផលក្នុងស្រុកសរុបបានធ្លាក់ចុះ ។ ចំពោះបញ្ហាអតិផរណា បន្ទាប់ពីអនុវត្តវិធានការជាកញ្ចប់របស់រាជរដ្ឋាភិបាលរួចមក បានថយចុះចាប់តាំងពីពាក់កណ្តាលឆ្នាំ២០០៨ និងបានធ្លាក់ចុះជាបន្តបន្ទាប់ ពីកម្រិតខ្ពស់បំផុត ៣៥.៦% នាខែឧសភា ឆ្នាំ២០០៨ រហូតដល់កម្រិតអវិជ្ជមាន -៤.៩% នាខែមិថុនា ឆ្នាំ២០០៩ ។ ការធ្លាក់ចុះនេះ ដោយសារតម្រូវការប្រើប្រាស់ទំនិញនៅទូទាំងពិភពលោកបានធ្លាក់ចុះ ។ នៅឆ្នាំ២០០៩ នេះ តាមការព្យាករណ៍របស់រាជរដ្ឋាភិបាល សេដ្ឋកិច្ចនឹងមានកំណើនក្នុងកម្រិត ២.១% ខ្ពស់ជាងការព្យាករណ៍បែបទុទិដ្ឋិនិយម របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ។

## II- លទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាអនុវត្តបានក្នុងឆមាសទី១ ឆ្នាំ២០០៨

ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធររូបិយវត្ថុជាតិ បានខិតខំបំពេញតួនាទីរបស់ខ្លួនក្នុងការរក្សាស្ថិរភាពថ្លៃ តាមរយៈការអនុវត្តនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន សំដៅរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ។

លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

ជាលទ្ធផល នៅឆមាសទី១ ឆ្នាំ២០០៩ នេះ ធនាគារជាតិនៃកម្ពុជាបានសម្រេចសមិទ្ធផលសំខាន់ៗ ដូចតទៅ :

ជារួមស្ថានភាពម៉ាក្រូសេដ្ឋកិច្ច នៅតែរក្សាភាពល្អប្រសើរនៃកំណើនជាប់ជាប្រចាំ ទោះបីជាអត្រាកំណើនមានការថយចុះបន្តិច និងទទួលរងនូវផលប៉ះពាល់ពីខាងក្រៅ ដែលធ្វើឱ្យអត្រាអតិផរណាកើនឡើងគួរឱ្យកត់សំគាល់បន្តិចក៏ដោយ ក៏អត្រាប្តូរប្រាក់ និងតម្លៃប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក មានស្ថិរភាពល្អប្រសើរ ដោយអត្រាប្តូរប្រាក់រៀលចុះថ្លៃប្រមាណ ២.៦% ក្នុងឆមាសទី១ ឆ្នាំ២០០៩ ធៀបនឹងគ្រាដូចគ្នា ឆ្នាំ២០០៨ ។ ស្ថិរភាពនៃតម្លៃប្រាក់រៀល បានរួមចំណែកពង្រឹងជំនឿទុកចិត្តរបស់សាធារណជនទូទៅចំពោះសេដ្ឋកិច្ចកម្ពុជា ។ ចំណែកឯការគ្រប់គ្រងទុនបម្រុងអន្តរជាតិ យើងអនុវត្តដោយឈរលើមូលដ្ឋានប្រុងប្រយ័ត្ន គឺសុវត្ថិភាព និងសាច់ប្រាក់-ងាយស្រួលជាចម្បង ។ គិតមកត្រឹមឆមាសទី១ឆ្នាំ២០០៩ ទុនបម្រុងអន្តរជាតិវិនិយោគរបស់យើងបានកើនឡើងជាង ២.៣៩៧ លានដុល្លារ ។

ក្រៅពីការចូលរួមពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាបានរួមចំណែកអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ របស់រាជរដ្ឋាភិបាល តាមដំណាក់កាល ហើយទទួលបានលទ្ធផលល្អប្រសើរ ដូចខាងក្រោម :

១)_វិស័យធនាគារ : មានការរីកចម្រើនទាំងវិសាលភាពនិងទំហំប្រតិបត្តិការ និងបានទទួលការគាំទ្រ និងជំនឿទុកចិត្តពីសាធារណជនទូទៅ ហើយបានដើរតួនាទីស្នូលក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។ នៅឆមាសទី១ឆ្នាំ២០០៩ នេះ ផ្នែកវិសាលភាព ធនាគារពាណិជ្ជកើនដល់ចំនួន ២៦ ដោយសារការចូលមកវិនិយោគរបស់វិនិយោគិនអាមេរិក កូរ៉េ ម៉ាឡេស៊ី វៀតណាម និងឥណ្ឌានាពេលថ្មីៗ នេះ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន ២០ ។ ចំណែកឯទំហំសកម្មភាពវិញ ទ្រព្យសកម្មសរុបកើនឡើង ៤.៥% ប្រាក់បញ្ញើកើន ១១.៨% និងឥណទានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុកើន ០.៦% ធៀបនឹងខែធ្នូ ឆ្នាំ២០០៨ ។

២)_ការងារត្រួតពិនិត្យធនាគារ : ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ យើងបានពង្រឹងការគ្រប់គ្រងប្រព័ន្ធធនាគារជាប់ជាប្រចាំ តាមរយៈការចុះទៅត្រួតពិនិត្យដល់ទីកន្លែង និងត្រួតពិនិត្យលើឯកសារ ដើម្បីជួយគ្រឹះស្ថានធនាគារទាំងនោះឱ្យពង្រឹងការគ្រប់គ្រង និងការងារសវនកម្មផ្ទៃក្នុងរបស់ខ្លួនឱ្យកាន់តែប្រសើរឡើង ព្រមទាំងឱ្យគ្រឹះស្ថានធនាគារទាំងនេះធ្វើការផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជាសាធារណៈ ដើម្បីបង្កើនជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារ ។ ការត្រួតពិនិត្យលើឯកសារ យើងបន្តអនុវត្តកម្មវិធីកុំព្យូទ័រកូប្រា (COBRA) ដើម្បីឱ្យការត្រួតពិនិត្យលើឯកសារកាន់តែស៊ីជម្រៅ និងមានសុក្រឹតភាព ។ ការត្រួតពិនិត្យដល់ទីកន្លែង យើងបន្តប្រើវិធីសាស្ត្រ CAMELS ដើម្បីវិភាគនិងវាយតម្លៃលើសុខភាពនិងសុវត្ថិភាពរបស់គ្រឹះស្ថានធនាគារនីមួយៗ ព្រមទាំងចេញអនុសាសន៍ឱ្យអនុវត្តតាមដើម្បីឱ្យធនាគារកាន់តែមានសុខភាពល្អ និងសុវត្ថិភាពខ្ពស់ថែមទៀត ។

នៅដើមឆ្នាំ២០០៩ នេះ ដោយសារស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចត្រូវបានពង្រឹង សម្ពាធអតិផរណាថយចុះ និងធនាគារនីមួយៗចេះគ្រប់គ្រងហានិភ័យដោយខ្លួនឯង យើងបន្ថយអត្រាប្រាក់បម្រុងកាតព្វកិច្ចពី ១៦% មក ១២% និងលុបចោលពិដានឥណទាន ១៥% វិញ ដើម្បីជម្រុញការផ្តល់ឥណទានបន្ថែមទៅដល់វិស័យសេដ្ឋកិច្ច និងរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការជម្រុញកំណើនសេដ្ឋកិច្ច និងរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ឆ្ពោះទៅលើកកំពស់ជីវភាពប្រជាជនឱ្យកាន់តែប្រសើរឡើង ស្របតាមយុទ្ធសាស្ត្រ ចតុកោណរបស់រាជរដ្ឋាភិបាល ដំណាក់កាលទី២ ។

៣).វិស័យមីក្រូហិរញ្ញវត្ថុ : មានការរីកចម្រើនយ៉ាងឆាប់រហ័ស និងមានហេដ្ឋារចនាសម្ព័ន្ធរឹងមាំដល់ជនបទ ហើយត្រូវបានទទួលស្គាល់ពីមជ្ឈដ្ឋានក្នុងនិងក្រៅប្រទេសថា **ជាវិស័យគន្លឹះក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា** ។ គិតត្រឹមឆមាសទី១ ឆ្នាំ២០០៩ នេះ ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសរុបចំនួន ១.១១៣ ពាន់លានរៀលធៀបនឹង ១.១៣០ ពាន់លានរៀល នៅឆមាសទី១ ឆ្នាំ២០០៨ គឺថយចុះចំនួន ៤% ប៉ុន្តែចំនួនអតិថិជនកើនដល់ ៨៧៣.៧៥០ នាក់ ។ ប្រាក់សន្សំប្រមូលបានចំនួន ៣០ ពាន់លានរៀល ពីអ្នកផ្ញើប្រាក់ចំនួន ១៥៨.៨៨៨ នាក់ ដោយកើនចំនួន ១៧% និង ២% រៀងគ្នា ធៀបនឹងគ្រាដូចគ្នានៃឆ្នាំ២០០៨ ។ ភាពជឿនលឿននេះ បញ្ជាក់ឱ្យឃើញថា ប្រជាពលរដ្ឋកម្ពុជាកាន់តែមានការយល់ដឹងពីសារៈសំខាន់នៃសេវាមីក្រូហិរញ្ញវត្ថុ និងវប្បធម៌ឥណទានកាន់តែប្រសើរឡើង ។

៤).ការពង្រឹងក្របខ័ណ្ឌច្បាប់ : ច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ ត្រូវប្រកាសឱ្យប្រើជាធរមានតាមព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៨ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៩ ។ ច្បាប់នេះ គឺជាមូលដ្ឋានគតិយុត្តសម្រាប់គៀងគរប្រភពទុនរយៈពេលវែងទៅអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម (SME) នៅកម្ពុជា និងកំណត់ឱ្យធនាគារជាតិនៃកម្ពុជាធ្វើជាអាជ្ញាធរអាណាព្យាបាលលើគ្រឹះស្ថានដែលធ្វើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ។ ទន្ទឹមនេះ យើងបានបន្តកែលំអរិធានការប្រុងប្រយ័ត្ននិងបទប្បញ្ញត្តិមួយចំនួន បានធ្វើចំណាត់ថ្នាក់ឥណទានតាមវិស័យ និងតាមកម្រិតហានិភ័យ ដើម្បីពង្រឹងប្រព័ន្ធធនាគារឱ្យប្រព្រឹត្តទៅដោយរលូន មានសុខភាពល្អ និងប្រសិទ្ធភាព ។

៥).អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ : ត្រូវបានរាជរដ្ឋាភិបាលបង្កើតឡើង ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីរួមចំណែកជាមួយសហគមន៍ជាតិ-អន្តរជាតិ ការពារទប់ស្កាត់ និងប្រឆាំងរាល់បទល្មើសទាក់ទងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។ ដើម្បីអនុវត្តតាមច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានសហការជាមួយនាយកដ្ឋានត្រួតពិនិត្យចុះទៅត្រួតពិនិត្យយន្តការអនុវត្តច្បាប់ ដើម្បីពិនិត្យមើលប្រតិបត្តិការសង្ស័យ និងរបាយការណ៍លំហូរសាច់ប្រាក់សង្ស័យរបស់គ្រឹះស្ថានធនាគារ ។

៦).ការពង្រឹងអភិបាលកិច្ច : ធនាគារជាតិនៃកម្ពុជាបានពង្រឹងការងារសវនកម្មផ្ទៃក្នុង និងការងារអធិការកិច្ច តាមរយៈការចេញប្រកាសមួយចំនួនពាក់ព័ន្ធនឹងការត្រួតពិនិត្យផ្ទៃក្នុង ។ ជាលទ្ធផល នៅឆមាសទី១ ឆ្នាំ២០០៩នេះ មន្ត្រីជំនាញយើង បានចុះធ្វើសវនកម្មនៅនាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និងនៅសាខាធនាគារជាតិនៃកម្ពុជាខេត្ត ចំនួន ៦ គឺ សាខាខេត្តរតនៈគិរី តាកែវ កំពង់ធំ កំពង់ស្ពឺ បន្ទាយមានជ័យ និងពោធិសាត់ ។

ម្យ៉ាងទៀត យើងបានកំពុងដំណើរការរៀបចំធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា ដែលហៅថាគម្រោងប្រព័ន្ធធនាគារស្នូល (CBS) ក្នុងគោលបំណងដើម្បី *១)*-ពង្រឹងតម្លាភាពនិងជួយសម្រួលប្រតិបត្តិការគ្រប់គ្រងលំហូរការងាររវាងនាយកដ្ឋានអាទិភាព ៤ គឺ នាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និងនាយកដ្ឋានគណនេយ្យ *២)*-ពន្លឿនប្រតិបត្តិការបើក-ដាក់ប្រាក់ ការបង់ពន្ធ និងការផ្ទេររវាងគណនី និង *៣)*-ដើម្បីឱ្យនាយកដ្ឋានទាំង ៤ ទទួលបានទិន្នន័យក្នុងពេលដំណាលគ្នា (Real time) ចំពោះប្រតិបត្តិការតែមួយ ។ គម្រោងប្រព័ន្ធធនាគារស្នូលនេះ បានចាប់ផ្តើមអនុវត្តការងារតាំងពីខែកុម្ភៈ ឆ្នាំ២០០៨ ដោយបែងចែកជា ៥ ដំណាក់កាល : *១)*-ការចងក្រងឯកសារដេញថ្លៃ *២)*-ការវាយតម្លៃលើការដេញថ្លៃ *៣)*-ការអនុវត្តបំពាក់ប្រព័ន្ធ *៤)*-ការបណ្តុះបណ្តាលមន្ត្រីជំនាញនិងការដាក់ឱ្យអនុវត្តសាកល្បង និង *៥)*-ការដាក់ឱ្យអនុវត្តពេញលេញនៅឆ្នាំ២០១០ ។

៧)*.ការពង្រឹងប្រតិបត្តិការសាខាធនាគារជាតិនៃកម្ពុជាខេត្ត* : គឺជាការងារអាទិភាពរបស់យើងដែលចាំបាច់ត្រូវពង្រឹងប្រតិបត្តិការរបស់ខ្លួនទាំងនៅទីស្នាក់ការកណ្តាល និងសាខាខេត្ត ដើម្បីចូលរួមអនុវត្តតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ជំហានទី ២ ។ ក្នុងគោលដៅនេះ យើងបានបង្កើនប្រសិទ្ធភាពគ្រប់គ្រងគណនីរដ្ឋ និងធ្វើឱ្យកាន់តែរលូនការបើកប្រាក់បៀវត្សជូនអង្គភាពរដ្ឋជុំវិញខេត្ត កងកម្លាំងប្រដាប់អាវុធ ក្រុមប្រឹក្សាឃុំ-សង្កាត់ និងបានទទួលចំណូលពន្ធដារនិងពន្ធគយ ។ ម្យ៉ាងទៀត ធនាគារជាតិនៃកម្ពុជាក៏បានធ្វើសវនកម្មនិងអធិការកិច្ចលើសាខាធនាគារជាតិនៃកម្ពុជាតាមខេត្ត សំដៅពង្រឹងប្រសិទ្ធភាពប្រតិបត្តិការ បន្ថែមទៀត ។

៨)*.ការអភិវឌ្ឍទីផ្សារអន្តរធនាគារ* : ដើម្បីអភិវឌ្ឍន៍ទីផ្សារអន្តរធនាគារ និងទីផ្សារមូលបត្រនៅកម្ពុជាស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២របស់រាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជាបានឯកភាពគ្នាចេញប្រកាសរួម ក្នុងជំហានដំបូងថា នឹងបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុអាចជួញដូរបានរយៈពេលខ្លី ដើម្បីជម្រុញដំណើរការបង្កើតទីផ្សារអន្តរធនាគារ និងទីផ្សារមូលបត្រនៅកម្ពុជា ។

ធនាគារជាតិនៃកម្ពុជាបានរៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិច្បាប់មួយចំនួនរួចហើយ ដើម្បីធ្វើមូលបត្រនីយកម្មប្រាក់បញ្ញើមានកាលកំណត់របស់បណ្តាធនាគារនៅធនាគារជាតិនៃកម្ពុជា ហើយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងពិចារណាអំពីការបោះផ្សាយឧបករណ៍ឥណទានរយៈពេលខ្លីដែលអាចជួញដូរបាន ក្នុងពេលសមស្របខាងមុខនេះ ស្របតាមនីតិវិធីច្បាប់ជាធរមាន ដើម្បីអភិវឌ្ឍទីផ្សារអន្តរធនាគារ និងទីផ្សារមូលបត្រនៅកម្ពុជា ។

៩)*.ការឈប់គ្រប់គ្រងអាជីវកម្មលក់ដូរគ្រឿងអលង្ការធ្វើពីលោហធាតុនិងត្បូងថ្មមានតម្លៃ* : តាមស្មារតីកិច្ចប្រជុំ កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩ នៅធនាគារជាតិនៃកម្ពុជា សម្រេចផ្ទេរប្រភេទអាជីវកម្មគ្រឿងអលង្ការ ឱ្យស្ថិតក្រោមសមត្ថកិច្ចក្រសួងពាណិជ្ជកម្មគ្រប់គ្រង ។ ពីមុន យើងធ្វើការគ្រប់គ្រងលើអាជីវកម្មលក់ដូរគ្រឿងអលង្ការ ដោយផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម ប៉ុន្តែបច្ចុប្បន្ន យើងឈប់ផ្តល់លិខិតអនុញ្ញាត

សម្រាប់ការធ្វើអាជីវកម្មនេះទៀតហើយ ព្រោះគ្រឿងអលង្ការមិនត្រូវបានចាត់ទុកជារូបិយប័ណ្ណទេ ។ ធនាគារជាតិនៃកម្ពុជា គ្រប់គ្រងតែសកម្មភាពធ្វើអាជីវកម្មលោហធាតុ និងត្បូងថ្មមានតម្លៃ ដែលចាត់ទុកជារូបិយប័ណ្ណប៉ុណ្ណោះ ។

**១០).សមាគមមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា :** បានបំពេញតួនាទីរបស់ខ្លួនយ៉ាងសកម្ម និងបានជួយរួមចំណែកដោះស្រាយការលំបាករបស់មន្ត្រីបុគ្គលិករបស់យើងបានមួយចំនួន និងបានទទួលការគាំទ្រយ៉ាងខ្លាំងពីមន្ត្រីបុគ្គលិករបស់យើង ។ ជាក់ស្តែង ទំហំនៃការលំបាករបស់មន្ត្រីបុគ្គលិកយើង មានលក្ខណៈខុសគ្នាពីម្នាក់ទៅម្នាក់ ពីមួយករណីទៅមួយករណី ដូច្នេះ សូមឱ្យសមាគមរបស់យើងធ្វើការពិចារណាលើបញ្ហានេះថែមទៀត ជាពិសេស ការឧបត្ថម្ភផ្នែកសុខភាព ។

លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

**១១).ចំពោះកិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិវិញ :** នៅឆមាសទី១ ឆ្នាំ២០០៩ នេះ ធនាគារជាតិនៃកម្ពុជា មានកិច្ចសហប្រតិបត្តិការជាមួយ :

**មូលនិធិរូបិយវត្ថុអន្តរជាតិ** (IMF) : ក្រុមបេសកកម្មបានបំពេញបេសកកម្មមួយលើកពីថ្ងៃទី១៩ ខែកុម្ភៈ ដល់ថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៩ និងបានកោតសរសើរធនាគារជាតិនៃកម្ពុជា ក្នុងការចាត់វិធានការថ្មីៗ ដើម្បីធ្វើឱ្យប្រសើរនូវការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល ការបង្កើតឧបករណ៍ឥណទានវិបារូបន៍ (OD) ការពង្រឹងប្រព័ន្ធចំណាត់ថ្នាក់ឥណទាន និងប្រព័ន្ធទុនបម្រុងកាតព្វកិច្ច ។ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានបន្តផ្តល់ជំនួយបច្ចេកទេសដល់ធនាគារជាតិនៃកម្ពុជា ដើម្បីពង្រឹងប្រសិទ្ធភាពការត្រួតពិនិត្យធនាគារថែមទៀត ។

**ធនាគារអភិវឌ្ឍន៍អាស៊ី :** ធនាគារជាតិនៃកម្ពុជា បានដើរតួនាទីស្នូលក្នុងការអនុវត្តអនុកម្មវិធីទី២ ចប់ដោយជោគជ័យ និងបន្តសហការជាមួយបណ្តាក្រសួងពាក់ព័ន្ធ អនុវត្តគម្រោងការងារនៅក្នុង អនុកម្មវិធីទី៣ ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០០៦-២០១៥ ។ ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ជំនួយបច្ចេកទេសដើម្បីរៀបចំធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់នាយកដ្ឋានស្នូលចំនួន ៤ ។

**ក្រុមប្រទេសអាស៊ាន** (ASEAN) : នៅឆមាសទី១ ឆ្នាំ២០០៩ នេះ ប្រតិភូធនាគារជាតិនៃកម្ពុជា បានចូលរួមជាប្រចាំក្នុងកិច្ចប្រជុំថ្នាក់នយោបាយ និងបច្ចេកទេសសំខាន់ៗរបស់អាស៊ាន ដែលកំពុងប្រឹងប្រែងជម្រុញកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន ដើម្បីពង្រឹងការតាមដានស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងតំបន់ អនុវត្តផែនទីបង្ហាញផ្លូវសន្និសីទសមាហរណកម្មរូបិយវត្ថុ-ហិរញ្ញវត្ថុអាស៊ាន និងអនុវត្តយុទ្ធសាស្ត្រសហគមន៍សេដ្ឋកិច្ចអាស៊ាន ។

**មជ្ឈមណ្ឌល SEACEN** :ប្រតិភូធនាគារជាតិនៃកម្ពុជាបានចូលរួមសន្និសីទថ្នាក់ទេសាភិបាលធនាគារកណ្តាលលើកទី៤៤ ស្តីពី ការអភិរក្សរូបិយវត្ថុនិងស្ថិរភាពហិរញ្ញវត្ថុ និងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល SEACEN លើកទី២៨ នៅទីក្រុងកូឡាឡំពួរ ប្រទេសម៉ាឡេស៊ី និងចូលរួមកិច្ចប្រជុំគណៈកម្មការប្រតិបត្តិ SEACEN លើកទី៧ (EXCO) នៅខេត្តយុគយ៉ាកាតា ប្រទេសឥណ្ឌូណេស៊ី ។ ធនាគារជាតិនៃកម្ពុជា ក៏បានបញ្ជូនមន្ត្រីជំនាញទៅចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលានានានៅក្នុង និងក្រៅប្រទេស ដែលរៀបចំឡើងដោយមជ្ឈមណ្ឌល SEACEN ផងដែរ ដើម្បីផ្លាស់ប្តូរបទពិសោធន៍គ្នា ។

ចំពោះកិច្ចសហប្រតិបត្តិការទ្វេភាគីវិញ ធនាគារជាតិនៃកម្ពុជាបានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលថៃ ធនាគារកណ្តាលវៀតណាម ធនាគារកណ្តាលឡាវ ធនាគារកណ្តាលម៉ាឡេស៊ី ធនាគារកណ្តាលកូរ៉េ ធនាគារកណ្តាលសិង្ហបុរី ធនាគារកណ្តាលអាឡឺម៉ង់ និងធនាគារកណ្តាលនៃបណ្តាប្រទេសអាស៊ានមួយចំនួនទៀត ដើម្បីផ្លាស់ប្តូរបទពិសោធន៍ក្នុងការគ្រប់គ្រងធនាគារកណ្តាល និងការបណ្តុះបណ្តាលមន្ត្រីជំនាញរបស់យើង ។

លោកជំទាវ ឯកឧត្តម អស់លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

សរុបមក សមិទ្ធផលទាំងឡាយដែលយើងមានសព្វថ្ងៃនេះ គឺកើតចេញពីការខិតខំប្រឹងប្រែងបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងការប្រើប្រាស់កម្លាំងសរុបរបស់មន្ត្រីបុគ្គលិកយើងទាំងអស់គ្នា ។ ដើម្បីជ្រាបពីសមិទ្ធផលលំអិតផ្សេងទៀត សូមអង្គសន្និបាតមេត្តាត្រងត្រាប់ស្តាប់បទឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំរបស់យើង ដែលនឹងរាយការណ៍ជូនអង្គសន្និបាតក្នុងពេលបន្តិចទៀតនេះ ។

ដើម្បីអបអរសាទរពិធីប្រារព្ធខួបអនុស្សាវរីយ៍លើកទី៣០ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ ដែលគ្រោងនឹងធ្វើនៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៩ ខាងមុខនេះ និងដើម្បីអបអរសាទរសមិទ្ធផលការងារ ដែលមន្ត្រីបុគ្គលិករបស់យើងបានរួមចំណែកកសាង ក្នុងរយៈពេល៣០ឆ្នាំ កន្លងមកនេះ ធនាគារជាតិនៃកម្ពុជាបានសម្រេចផ្តល់សញ្ញាមាសអនុស្សាវរីយ៍ធនាគារជាតិនៃកម្ពុជា ជូនមន្ត្រីបុគ្គលិក : *ទី១)*-ថ្នាក់ដឹកនាំចាប់ពីអនុប្រធាននាយកដ្ឋានឡើងទៅ និង *ទី២)*-មន្ត្រីបុគ្គលិកដែលបានបម្រើការងាររយៈពេល ៣០ឆ្នាំ ចាប់តាំងពីឆ្នាំ១៩៧៩ មកសរុបទាំងអស់ចំនួន ១៣៤ រូប ទាំងនៅទីស្នាក់ការកណ្តាល និងនៅសាខាខេត្ត ។ យើងបន្តធ្វើពិធីបែបនេះនៅឆ្នាំក្រោយទៀត ជាបន្តបន្ទាប់ ។

ទន្ទឹមពេលនេះដែរ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការ និងការខិតខំប្រឹងប្រែងរបស់សមាជិកក្រុមប្រឹក្សាភិបាលនិងមន្ត្រីបុគ្គលិកទាំងអស់ ដែលបានរួមចំណែកកសាងធនាគារជាតិនៃកម្ពុជា ទទួលបានលទ្ធផលល្អប្រសើរគួរជាទីមោទនៈ ។ ខ្ញុំនៅតែមានជំនឿជឿជាក់ថា លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា នៅតែបន្តស្មារតីសាមគ្គីគ្នាជាប្រពៃណីនេះតទៀត ។ អង្គសន្និបាតរបស់យើងនឹងប្រព្រឹត្តទៅរយៈពេលពីរថ្ងៃ សូម លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ខិតខំស្តាប់របាយការណ៍ស្តីពីលទ្ធផលការងារដែលបានអនុវត្តកន្លងមក និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០០៩ សំរាប់អនុវត្តឱ្យបានជោគជ័យ ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់ លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ដែលមានវត្តមាននៅក្នុងអង្គសន្និបាតនេះ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ហើយទន្ទឹមនេះ សូមឱ្យអង្គសន្និបាតរបស់យើងថ្ងៃនេះមានដំណើរការប្រកបដោយជោគជ័យ ។

ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ ។

**សូមអរគុណ !**